រៀបរៀងដោយ វេជ្ជ.ហោង ណៃឃីម / វេជ្ជ.ពឹង យ៉ឹកស៊ីង / ខែមេសា ឆ្នាំ២០១៥

# វ៉ាក់សាំងបង្ការជំងឺរលាកខួរក្បាល ( JE Vaccine )

## ១- ហេតុអ្វីអ្នកត្រូវទទួលវ៉ាក់សាំងប្រភេទនេះ?

ជំងឺរលាកខួរក្បាល (Japanese Encephalitis or JE) គឺជាជំងឺបង្កពោគដោយវីរុស។

- វារាតត្បាតយ៉ាងខ្លាំង នៅតាមតំបន់ជនបទ ដាច់ស្រយាលនៃទ្វីបអាស៊ី។
- វាចំលងមកមនុស្ស តាមរយៈសត្វមូសដែលមានផ្ទុកមេរោគនេះខាំ។ វាមិនចំលងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតដោយផ្ទាល់ឡើយ។
- ការប្រឈមនឹងជំងឺនេះមានអត្រាឆ្លងខ្ពស់ណាស់ សំរាប់មនុស្សរស់នៅតំបន់ដែលជំងឺនេះរាតត្បាតញឹកញាប់ រឺអ្នកដំណើរដែលស្នាក់នៅតំបន់ទាំងនោះ ក្នុងរយៈពេលយូរ។
- មនុស្សភាគច្រើនដែលបានឆ្លងមេរោគរលាកខួរក្បាលនេះ មិនមានចេញរោគសញ្ញាអ្វីឡើយ។
- មនុស្សមួយចំនួនតូចអាចមានចេញរោគសញ្ញាកំរិតស្រាលដូចជា គ្រុនក្តៅ រឺឈឺក្បាលប៉ុណ្ណោះ។ វាអាចមានអាការៈធ្ងន់ធ្ងរ ដោយវិវត្តន៍ជាទំរង់រលាកខួរក្បាលធ្ងន់ធ្ងរ តែករណីនេះកម្រនឹងកើតមានណាស់។
- ក្នុងទំរង់រលាកខួរក្បាលនេះ អ្នកជំងឺម្នាក់ក្នុងចំណោមបួននាក់អាចស្លាប់បាត់បង់ជីវិត ហើយរហូតដល់ពាក់កណ្តាលនៃអ្នកជំងឺដែលនៅរស់រានមានជីវិត ជំងឺនេះបន្សល់នូវពិការភាពជាអចិន្ត្រៃយ៍។
- ប្រសិនបើជំងឺរលាកខួរក្បាលនេះកើតលើស្ត្រីមានផ្ទៃពោះ វាអាចបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ទារកក្នុងផ្ទៃ។

## ២- តើអ្នកណាខ្លះគួរទទួលវ៉ាក់សាំងបង្ការជំងឺរលាកខួរក្បាលនេះ? ហើយគួរទទួលនៅពេលណា?

**វ៉ាក់សាំងបង្ការជំងឺរលាកខួរក្បាលអាចជួយការពារអ្នកពីការឆ្លងជំងឺនេះបាន។**

វ៉ាក់សាំងនេះត្រូវបានណែនាំអោយប្រើសំរាប់៖

១- អ្នកដែលរស់នៅតំបន់ដែលប្រឈមនឹងជំងឺនេះ

២- អ្នកដំណើរដែលស្នាក់នៅក្នុងតំបន់ប្រឈមនឹងជំងឺនេះ លើសពី ១ខែ

៣- អ្នកដំណើរដែលស្នាក់នៅតំបន់ដែលប្រឈមនឹងជំងឺនេះ តិចជាង ១ខែ តែមានគំរោងធ្វើដំណើរទៅតំបន់ជនបទ

៤- អ្នកដែលមានគំរោងធ្វើដំណើរទៅកាន់តំបន់ដែលកំពុងមានការរាតត្បាលដោយជំងឺនេះ

៥- អ្នកមន្ទីរពិសោធន៍ដែលប្រឈមនឹងមេរោគនេះ

វ៉ាក់សាំងបង្ការជំងឺរលាកខួរក្បាលនេះត្រូវបានប្រើប្រាស់ សំរាប់មនុស្សដែលមានអាយុ ចាប់ពី ៩ខែ ឡើងទៅ ដោយត្រូវធ្វើចំនួន២ដង៖

- ដូសទី១: ចាប់ពីអាយុ ៩ខែ ឡើងទៅ
- ដូសទី២: ៣ខែ ទៅ ១ឆ្នាំ បន្ទាប់ពីដូសទី១

## ៣- តើអ្នកណាខ្លះដែលមិនគួរចាក់វ៉ាក់សាំងនេះ?

- អ្នកដែលធ្លាប់មានប្រវត្តិប្រតិកម្មធ្ងន់ធ្ងរជាមួយនឹងវ៉ាក់សាំងប្រភេទនេះពីមុន ឬធ្លាប់ប្រតិកម្មធ្ងន់ធ្ងរជាមួយសមាសធាតុផ្សំផ្សេងទៀតដែលមានក្នុងថ្នាំវ៉ាក់សាំងនេះ
- ស្ត្រីដែលកំពុងមានផ្ទៃពោះ
- អ្នកដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយ
- អ្នកដែលបានបញ្ចូលឈាម ក្នុងពេលថ្មីៗ នេះ

## ៤- ផលវិបាកដែលអាចកើតមានក្រោយចាក់វ៉ាក់សាំង

ក៏ដូចជាឱសថផ្សេងៗទៀតដែរ វ៉ាក់សាំងអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរ ដូចជាប្រតិកម្មអាលែកស៊ីជាដើម។ ប៉ុន្តែលទ្ធភាពដែលវ៉ាក់សាំងនេះអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរ មានតិចតួចបំផុត។ ផលវិបាកដែលអាចកើតឡើងរួមមាន៖

- ឈឺ ឬហើមត្រង់កន្លែងចាក់
- គ្រុនក្តៅ ឈឺក្បាល ឈឺសាច់ដុំ
- ឡើងកន្ទួលក្រហមលើស្បែក និងចង្អោរ
- ប្រតិកម្មធ្ងន់ធ្ងរ (កំរមានណាស់)

**ប្រសិនបើមានសញ្ញាប្រតកម្មធ្ងន់ធ្ងរ សូមជូនដំណឹងដល់គ្រូពេទ្យជាបន្ទាន់!**